| ៤៦៤- | លោកស្រី | ពី | សុផា | សិក្ខាបនធារី | សាលាបឋមសិក្សាមុខប៉ែន | ពួក |
| ៤៦៥- | លោកស្រី | ឡុន | ប៊ុនអ៊ាង | សិក្ខាបនធារី | សាលាបឋមសិក្សាដំណាក់ស្ពាញ | ពួក |
| ៤៦៦- | លោក | តន់ | នី | សិក្ខាបនធារី | សាលាបឋមសិក្សាត្រកៀត | ពួក |
| ៤៦៧- | លោកស្រី | យ៉េម | គិមឈុំ | សិក្ខាបនធារី | សាលាបឋមសិក្សាប្រាសាទ | ពួក |
| ៤៦៨- | លោកស្រី | ស៊ី | ថន | សិក្ខាបនធារី | សាលាបឋមសិក្សាគោកខ្ពស់ | ពួក |
| ៤៦៩- | លោកស្រី | ជា | ដំណ្ណា | សិក្ខាបនធារី | សាលាបឋមសិក្សាអំពិលពាម | ពួក |
| ៤៧០- | លោក | ព្រឿន | ឆុន | សិក្ខាបនធារី | សាលាបឋមសិក្សាក្តីរុន | ពួក |
| ៤៧១- | លោកស្រី | ទ៉ាត | សុខុម | សិក្ខាបនធារី | សាលាបឋមសិក្សាយាង | ពួក |
| ៤៧២- | លោកស្រី | កង | សុតាព | សិក្ខាបនធារី | សាលាបឋមសិក្សាដូនទ្រ | ពួក |
| ៤៧៣- | លោកស្រី | ហ៊ឹម | លីន | សិក្ខាបនធារី | សាលាបឋមសិក្សាស្ទឹងព្រះស្រុក | ពួក |
| ៤៧៤- | លោកស្រី | ហ៊ិន | គិមអយ | សិក្ខាបនធារី | សាលាបឋមសិក្សាពួក | ពួក |
| ៤៧៥- | លោកស្រី | ឈា | ទិទ្ធិកា | សិក្ខាបនធារី | សាលាបឋមសិក្សាពួក | ពួក |
| ៤៧៦- | លោក | សេង | ពៅ | សិក្ខាបនធារី | សាលាបឋមសិក្សានាមរូប | ពួក |
| ៤៧៧- | លោក | ប៊ិន | សិទ្ធ | សិក្ខាបនធារី | សាលាបឋមសិក្សាគោកធ្លៅ | ពួក |
| ៤៧៨- | លោកស្រី | ជា | សម្បត្តិ | សិក្ខាបនធារី | វិទ្យាល័យពួក | ពួក |
| ៤៧៩- | លោកស្រី | ម៉ាង | សារឿម | សិក្ខាបនធារី | វិទ្យាល័យពួក | ពួក |
| ៤៨០- | លោក | សម្ប | សុធា | សិក្ខាបនធារី | វិទ្យាល័យពួក | ពួក |
| ៤៨១- | លោក | អ៊ិត | សំអាន | សិក្ខាបនធារី | សាលាបឋមសិក្សារើល | ពួក |

| | | | | | | |
|---|---|---|---|---|---|---|
| ៤៨២- | លោក | យូ | ផល្លី | សិក្ខាបនធារី | សាលាបឋមសិក្សាអធិបតី | ពួក |
| ៤៨៣- | លោកស្រី | ហេម | ហៅ | សិក្ខាបនធារី | សាលាបឋមសិក្សាជ្ជួយចក្រី | ពួក |
| ៤៨៤- | លោក | ធន់ | ផល | សិក្ខាបនធារី | សាលាបឋមសិក្សាតាអាន | ក្រឡាញ់ |
| ៤៨៥- | លោកស្រី | ព្រិម | ម៉ាលី | សិក្ខាបនធារី | សាលាបឋមសិក្សាក្រឡាញ់ | ក្រឡាញ់ |
| ៤៨៦- | លោកស្រី | នឿត | ឌី | សិក្ខាបនធារី | បឋមសិក្សាប្រាសាទខ្នារ | ក្រឡាញ់ |
| ៤៨៧- | លោក | ថៃ | ថា | សិក្ខាបនធារី | សាលាបឋមសិក្សាល្បើកប្រិយ៍ | ក្រឡាញ់ |
| ៤៨៨- | លោក | ហឿត | ចាន់ថន | សិក្ខាបនធារី | សាលាបឋមសិក្សាភូមិគំរូ | ក្រឡាញ់ |
| ៤៨៩- | លោក | តិច | សុខា | សិក្ខាបនធារី | សាលាបឋមសិក្សាភូមិគំរូ | ក្រឡាញ់ |
| ៤៩០- | លោក | ផាង | សុផារីប | សិក្ខាបនធារី | សាលាបឋមសិក្សាតាសែង | ក្រឡាញ់ |
| ៤៩១- | លោក | រស់ | ចិន្តា | សិក្ខាបនធារី | សាលាបឋមសិក្សាព្រៃល្វៀង | ក្រឡាញ់ |
| ៤៩២- | លោកស្រី | មិត្ត | ហ៊ីង | សិក្ខាបនធារី | វិទ្យាល័យ២៨មករា | ស្រីស្នំ |
| ៤៩៣- | លោក | សាន | សុផា | សិក្ខាបនធារី | អនុវិទ្យាល័យគោកថ្កូវ | ស្រីស្នំ |
| ៤៩៤- | លោក | ហួន | អូយ | សិក្ខាបនធារី | អនុវិទ្យាល័យគោកថ្កូវ | ស្រីស្នំ |
| ៤៩៥- | លោក | ឈួយ | សុខា | សិក្ខាបនធារី | អនុវិទ្យាល័យចំការចេក | ស្រីស្នំ |
| ៤៩៦- | លោក | ពើយ | សំអុល | សិក្ខាបនធារី | សាលាបឋមសិក្សាគោកថ្កូវ | ស្រីស្នំ |
| ៤៩៧- | លោកស្រី | រ៉ែម | តុត្រា | សិក្ខាបនធារី | សាលាបឋមសិក្សារំដេង | ស្រីស្នំ |
| ៤៩៨- | លោកស្រី | ឡិប | សារ៉ាម | សិក្ខាបនធារី | សាលាបឋមសិក្សាគោកព្រេច | ស្រីស្នំ |
| ៤៩៩- | លោក | ទៅ | សឺង | សិក្ខាបនធារី | សាលាបឋមសិក្សាសាលា | ស្រីស្នំ |
| ៥០០- | លោក | ចាត | ឡៀង | សិក្ខាបនធារី | សាលាបឋមសិក្សាចារ | ស្រីស្នំ |
| ៥០១- | លោក | ស៊ាក់ | ស៊ីនួន | សិក្ខាបនធារី | សាលាបឋមសិក្សាធ្លកត្រាំកង់ | ស្រីស្នំ |
| ៥០២- | លោកស្រី | ពោធ | រី | សិក្ខាបនធារី | សាលាបឋមសិក្សាភ្នំស្រីស្នំ | ស្រីស្នំ |
| ៥០៣- | លោកស្រី | រី | ហ៊ាន់ | សិក្ខាបនធារី | សាលាបឋមសិក្សាគ្រួសារយ៉េតចារកា | អង្គរជុំ |
| ៥០៤- | លោកស្រី | សេង | ពិសី | សិក្ខាបនធារី | សាលាបឋមសិក្សាតាលាវ | អង្គរជុំ |
| ៥០៥- | លោក | តិក | លីហ៊ាន | សិក្ខាបនធារី | សាលាបឋមសិក្សាខាន់ស | អង្គរជុំ |
| ៥០៦- | លោកស្រី | ធាន | ចេក | សិក្ខាបនធារី | សាលាបឋមសិក្សាតាទយ | អង្គរជុំ |
| ៥០៧- | លោក | ថ្លាង | ហំសចតី | សិក្ខាបនធារី | វិទ្យាល័យអង្គរជុំ | អង្គរជុំ |
| ៥០៨- | លោកស្រី | ឆាំ | សុតាថី | សិក្ខាបនធារី | សាលាបឋមសិក្សាតាទយ | អង្គរជុំ |
| ៥០៩- | លោក | ឃុត | ម៉ឺង | សិក្ខាបនធារី | សាលាបឋមសិក្សាគ្រួសារយ៉េតចារកា | អង្គរជុំ |
| ៥១០- | លោក | ឌុច | ថារ: | សិក្ខាបនធារី | អនុវិទ្យាល័យដូនពេង | អង្គរជុំ |
| ៥១១- | លោកស្រី | ស៊ី | រក្សូ | សិក្ខាបនធារី | បឋមសិក្សាប្រាសាទគោល | អង្គរជុំ |
| ៥១២- | លោក | លី | សុថៃ | សិក្ខាបនធារី | វិទ្យាល័យគោកដូង | អង្គរជុំ |

| | | | | | | |
|---|---|---|---|---|---|---|
| ៥១៣- | លោក | ចិត | សំរេច | សិក្ខាបនធារី | បឋមសិក្សាប្រាសាទគោល | អង្គរជុំ |
| ៥១៤- | លោក | ពុយ | ហួរ | សិក្ខាបនធារី | អនុវិទ្យាល័យនគរភាស | អង្គរជុំ |
| ៥១៥- | លោក | សាន់ | សាទថ់ | សិក្ខាបនធារី | សាលាបឋមសិក្សាប្រាសាទ | វ៉ារិន |
| ៥១៦- | លោកស្រី | ណេខ | សុគំន្ធ | សិក្ខាបនធារី | សាលាបឋមសិក្សាប្រាសាទ | វ៉ារិន |
| ៥១៧- | លោក | ទៀច | ទង់ | សិក្ខាបនធារី | សាលាបឋមសិក្សាចន្ទគីរី | វ៉ារិន |
| ៥១៨- | លោក | សារ៉ូខ | ស៊ីថា | សិក្ខាបនធារី | សាលាបឋមសិក្សាចារ | វ៉ារិន |
| ៥១៩- | លោក | គាត | សុគុណា | សិក្ខាបនធារី | សាលាបឋមសិក្សាវៀន | វ៉ារិន |
| ៥២០- | លោក | ឈត់ | គុខគី | សិក្ខាបនធារី | សាលាបឋមសិក្សាប្រាសាទ | វ៉ារិន |
| ៥២១- | លោកស្រី | ចេខ | ចាន់រ៉ា | សិក្ខាបនធារី | សាលាបឋមសិក្សាចារ | វ៉ារិន |
| ៥២២- | លោកស្រី | ឡូញ | សាលី | សិក្ខាបនធារី | សាលាបឋមសិក្សាកញ្ជន់រុន | វ៉ារិន |
| ៥២៣- | លោកស្រី | សារឿន | ណាទាយ | សិក្ខាបនធារី | សាលាបឋមសិក្សាវ៉ារិន | វ៉ារិន |
| ៥២៤- | លោក | ឆិញ | រំ | សិក្ខាបនធារី | សាលាបឋមសិក្សាវ៉ារិន | វ៉ារិន |
| ៥២៥- | លោកស្រី | ភេន | ស៊ីហា | សិក្ខាបនធារី | សាលាបឋមសិក្សាកញ្ជន់រុន | វ៉ារិន |
| ៥២៦- | លោក | ធេព | ថា | សិក្ខាបនធារី | សាលាបឋមសិក្សាលាងដៃ | អង្គរធំ |
| ៥២៧- | លោក | ហ៊ុន | ម៉ុនជួយ | សិក្ខាបនធារី | វិទ្យាល័យហ៊ុនសែនអង្គរធំ | អង្គរធំ |
| ៥២៨- | លោកស្រី | លឿម | គួន | សិក្ខាបនធារី | សាលាបឋមសិក្សាគោកត្រើល | អង្គរធំ |
| ៥២៩- | លោកស្រី | ទន់ | សុគី | សិក្ខាបនធារី | សាលាបឋមសិក្សាលាងដៃ | អង្គរធំ |
| ៥៣០- | លោកស្រី | ភុច | ហឿត | សិក្ខាបនធារី | សាលាបឋមសិក្សាដូនឱ | អង្គរធំ |
| ៥៣១- | លោកស្រី | ស៊ា | យ៉េត | សិក្ខាបនធារី | សាលាបឋមសិក្សាស្វាយចេក | អង្គរធំ |
| ៥៣២- | លោកស្រី | ឌូ | គន្ធី | សិក្ខាបនធារី | សាលាបឋមសិក្សាសណ្តាន់ | អង្គរធំ |
| ៥៣៣- | លោកស្រី | គៅ | សុខា | សិក្ខាបនធារី | សាលាបឋមសិក្សាតាប្រុក | អង្គរធំ |
| ៥៣៤- | លោកស្រី | ម្រ៉ឹត | ចិន្តា | សិក្ខាបនធារី | សាលាបឋមសិក្សាពាក់ស្នែង | អង្គរធំ |
| ៥៣៥- | លោកស្រី | ប៉ែន | ឌីណា | សិក្ខាបនធារី | វិទ្យាល័យបន្ទាយស្រី | បន្ទាយស្រី |
| ៥៣៦- | លោកស្រី | ជា | សាឌីម | សិក្ខាបនធារី | អនុវិទ្យាល័យរំចេក | បន្ទាយស្រី |
| ៥៣៧- | លោកស្រី | នុត | សុតា | សិក្ខាបនធារី | អនុវិទ្យាល័យតៀង | បន្ទាយស្រី |
| ៥៣៨- | លោក | ផ្លង់ | លីន | សិក្ខាបនធារី | អនុវិទ្យាល័យខ្នារសណ្តាយ | បន្ទាយស្រី |

| | | | | | | |
|---|---|---|---|---|---|---|
| ៥៣៩- | លោកស្រី | ម៉ែន | ផានិត | សិក្ខាបនធារី | សាលាបឋមសិក្សាខ្វារ | បន្ទាយស្រី |
| ៥៤០- | លោកស្រី | គាំ | សុខុម | សិក្ខាបនធារី | សាលាបឋមសិក្សាតានី | បន្ទាយស្រី |
| ៥៤១- | លោកស្រី | ម៉ឿន | ខេង | សិក្ខាបនធារី | សាលាបឋមសិក្សារហាល | បន្ទាយស្រី |
| ៥៤២- | លោកស្រី | ចាយ | ឡឹមលាង | សិក្ខាបនធារី | សាលាបឋមសិក្សាត្បែង | បន្ទាយស្រី |
| ៥៤៣- | លោក | ឌុច | ដារ៉ា | សិក្ខាបនធារី | សាលាបឋមសិក្សាព្រះអង្គធំ | ស្វាយលើ |
| ៥៤៤- | លោក | ហឿន | សុហេន | សិក្ខាបនធារី | សាលាបឋមសិក្សាត្រពាំងស្វាយ | ស្វាយលើ |
| ៥៤៥- | លោកស្រី | អាន | សុនិច | សិក្ខាបនធារី | បឋមសិក្សាហ៊ុនសែនស្វាយលើ | ស្វាយលើ |
| ៥៤៦- | លោក | អាន | អេង | សិក្ខាបនធារី | សាលាបឋមសិក្សាស្រែរបង | ស្វាយលើ |
| ៥៤៧- | លោក | សោ | ប៊ុនធឿន | សិក្ខាបនធារី | សាលាបឋមសិក្សាទឹកលិច | ស្វាយលើ |
| ៥៤៨- | លោកស្រី | ម៉ៃ | សុខុន | សិក្ខាបនធារី | សាលាបឋមសិក្សាសក្តា | ស្វាយលើ |

**មា-ត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ , ខេត្តសៀមរាប និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៣៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា១.**_បំពាក់**មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន៨រូប ដែលមានស្នាព្រះហស្ត-ស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា លើការអភិវឌ្ឍវិស័យពុទ្ធិចក្រ និងអាណាចក្រក្នុងមូលដ្ឋាន អោយមានការរីកចម្រើនជាបន្តបន្ទាប់ស្ថិតក្នុងឃុំចាន់មូល ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កន្លងមក ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | | |
|---|---|---|---|
| -លោក | **ទូន** | **សុផល** | សប្បុរសជន |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | | |
|---|---|---|---|
| ១-លោក | **ស្រ៊ន់** | **ពិធូ** | សប្បុរសជន |
| ២-លោក | **អ៊ិន** | **សុទន្ត** | សប្បុរសជន |
| ៣-លោក | **គីម** | **ផល្លី** | សប្បុរសជន |
| ៤-អ្នកស្រី | **ង៉ូយ** | **គីមសែន** | សប្បុរសជន |
| ៥-អ្នកស្រី | **បែន** | **ចរិយា** | សប្បុរសជន |

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សប្ញទ្ធិ**

| | | | |
|---|---|---|---|
| ១-ព្រះភិក្ខុ | **ឡឿ** | **យឹម** | ព្រះចៅអធិការវត្តឧដុង្គមានជ័យ |
| ២-អ្នកស្រី | **ប្រាក់** | **សុគន់** | សប្បុរសជន |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩៣៧-អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយសំរឹទ្ធស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន២៥រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា លើការអភិវឌ្ឍវិស័យពុទ្ធិចក្រ និងអាណាចក្រក្នុងមូលដ្ឋាន អោយមានការរីកចម្រើនជាបន្តបន្ទាប់ ស្ថិតក្នុងឃុំចាន់មូល ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | **ព្រុំ** | **ស៊ុន** | សប្បុរសជន |
| ២-អ្នកស្រី | **ប្រាក់** | **កក្កដា** | សប្បុរសជន |
| ៣-លោក | **ឃួន** | **គជារិទ្ធ** | សប្បុរសជន |
| ៤-លោក | **ឯក** | **យឿន** | សប្បុរសជន |
| ៥-លោក | **ព្រុំ** | **សំអុល** | សប្បុរសជន |
| ៦-លោក | **ប្រាក់** | **គឹមជឿន** | សប្បុរសជន |
| ៧-លោក | **យន់** | **យ៉ឺន** | សប្បុរសជន |
| ៨-លោក | **គង់** | **សុទ្ធ** | សប្បុរសជន |
| ៩-លោក | **មាន** | **ទី** | សប្បុរសជន |
| ១០-លោក | **មួម** | **ឈាង** | សប្បុរសជន |
| ១១-លោក | **អ៊ុច** | **អឿន** | សប្បុរសជន |
| ១២-លោក | **ធុច** | **ថន** | សប្បុរសជន |
| ១៣-លោក | **តូច** | **ស៊ុំ** | សប្បុរសជន |
| ១៤-លោក | **ជួប** | **សារុធ** | សប្បុរសជន |
| ១៥-លោក | **ទេព** | **សារុន** | សប្បុរសជន |

| | | | |
|---|---|---|---|
| ១៦-លោក | ជ្រឹង | ជឿន | សប្បុរសជន |
| ១៧-លោក | យ៉ាន | សាន់ | សប្បុរសជន |
| ១៨-លោក | អ៊ិន | ចន | សប្បុរសជន |
| ១៩-លោក | សន | វ៉ន | សប្បុរសជន |
| ២០-លោក | ប៊ិន | ញ៉ | សប្បុរសជន |
| ២១-លោក | កែប | ជ្រឹង | សប្បុរសជន |
| ២២-លោក | ព្រុំ |ឈឿន | អាចារ្យឧដុង្គមានជ័យ |
| ២៣-លោក | ម៉ូវ | ឈឿន | គណៈកម្មការវត្តឧដុង្គមានជ័យ |
| ២៤-លោក | សុខ | យ៉ាន | គណៈកម្មការវត្តឧដុង្គមានជ័យ |
| ២៥-លោក | មៀវ | សែម | គណៈកម្មការវត្តឧដុង្គមានជ័យ |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៧ អនក្រ.សរ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពនៃគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ១៣៣អនក្រ.បកចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើត ការគ្រប់គ្រងនិងការចាត់ចែងមូលនិធិទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ និងការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១ .–**

ត្រូវបានតែងតាំងសមាសភាពនៃគណៈកម្មាធិការទ្រទ្រង់និងអភិវឌ្ឍសិល្បៈជាតិ( **ម.ស.ជ.** ) ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | លោកជំទាវ | **ភឿង សកុណា** | រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| ២- | ឯកឧត្តម | **ជួ គីមឡេង** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្តម | **សោម សុគន្ធ** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- | ឯកឧត្តម | **ប៉ាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៥- | ឯកឧត្តម | **ជា ច័ន្ទបរិបូរណ៍** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ៦- | ឯកឧត្តម | **ម៉ក់ សម្បត្តិ** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- | ឯកឧត្តម | **ឆ្ងួច សារ៉ូ** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨- | ឯកឧត្តម | **ហាប់ ទូច** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ | លេខាធិការអចិន្ត្រៃយ៍។ |

**ប្រការ២ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១០៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបំពេញបន្ថែមសមាជិកក្រុមការងារ ថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទីភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ១.—**

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តស្វាយរៀង និងរាជធានីភ្នំពេញ ដែលមានរាយនាមដូចខាងក្រោម៖

១-ខេត្តស្វាយរៀង

១- ឯកឧត្តម **ជៀង អំ** រដ្ឋលេខាធិការក្រសួងការពារជាតិ

២- លោកជំទាវ **ខាន់ មយុរា** អនុរដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

៣- ឯកឧត្តម ឧត្តមសេនីយ៍ទោ **មួន សាម៉េត** មេបញ្ជាការរងកងទ័ពពិសេសឆ័ត្រយោង៩១១ ក្រសួងការពារជាតិ

២-រាជធានីភ្នំពេញ

១- ឯកឧត្តម **ម៉េង ពោធិ៍នា** អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន

**ប្រការ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តស្វាយរៀង រដ្ឋបាលរាជធានីភ្នំពេញ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១៦

**តប. នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...១០៥...សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបំពេញបន្ថែមសមាជិកក្រុមការងារ ថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តកំពង់ស្ពឺនិងខេត្តព្រះសីហនុ ដូចខាងក្រោមៈ

១-ខេត្តកំពង់ស្ពឺ

១-ឯកឧត្តម **អ៊ុ សំអូន** រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

២-ខេត្តព្រះសីហនុ

២-ឯកឧត្តម **ម៉ើង លីដា** ទីប្រឹក្សាសម្តេចក្រឡាហោម សមាជិក

**ប្រការ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តកំពង់ស្ពឺ រដ្ឋបាលខេត្តព្រះសីហនុ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១៦

**ស.ច. នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:១០៧ សសរ**

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងាររួមស្តីពីកិច្ចសហប្រតិបត្តិការ
# រវាង
# រាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងាររួមកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ហៅកាត់ថា (គ.ស.អ.អ) សម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម វិនិយោគ និងសេដ្ឋកិច្ច រវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី។

**ប្រការ ២.-**

សេចក្តីសម្រេចនេះ មានគោលបំណង៖

- ធានាប្រសិទ្ធភាពនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី
- ជំរុញ និងបង្កើនប្រសិទ្ធភាព កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម វិនិយោគ និងសេដ្ឋកិច្ចទូលំទូលាយ
- អភិវឌ្ឍន៍ និងពង្រីកទំហំពាណិជ្ជកម្មរវាងព្រះរាជាណាចក្រកម្ពុជា និងសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី និងជំរុញកិច្ចសម្រួលពាណិជ្ជកម្ម។

## ជំពូកទី២
## សមាសភាព

**ប្រការ ៣.-**

ក្រុមការងាររួមកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី សម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម វិនិយោគ និងសេដ្ឋកិច្ចកម្ពុជា-សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. លោកជំទាវ **គឹមរ៉េត អំរង** រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥. តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៦. តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៩. តំណាងក្រុមប្រឹក្សាអ្នកច្បាប់កម្ពុជា | សមាជិក |
| ១០. តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១១. តំណាងនាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក នៃក្រសួងពាណិជ្ជកម្ម | លេខាធិការ |

សមាជិកក្រុមការងាររួមកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី អាចត្រូវបាន បន្ថែមសមាសភាព ដោយប្រធានគណៈកម្មការនេះទៅតាមការចាំបាច់។

## ជំពូកទី៣
## តួនាទី និងភារកិច្ច

**ប្រការ ៤.-**

ក្រុមការងាររួមកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី សម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម វិនិយោគ និងសេដ្ឋកិច្ចកម្ពុជា-សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី មានតួនាទី និងភារកិច្ច (សម្របសម្រួល) ដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការសកម្មភាព សម្រាប់ជំរុញ និងគាំទ្រដល់ការពង្រីកកិច្ចសហប្រតិបត្តិការ សម្របសម្រួលពាណិជ្ជកម្ម និងលើកកម្ពស់ការវិនិយោគលើវិស័យអាទិភាព និងត្រូវធានាឲ្យមានភាពស្របគ្នាជាមួយនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល។

- ជំរុញកិច្ចសហប្រតិបត្តិការលើវិស័យ សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងសេវាកម្មផ្សេងៗ រវាងសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី និងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- ចូលរួមសិក្សាពីលទ្ធភាពបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (Free Trade Agreement) ដើម្បីឱ្យដឹងពីផលប្រយោជន៍ និងផលប៉ះពាល់ក្នុងការបង្កើត Free Trade Agreement នេះ។
- ស្វែងយល់អំពីខ្លឹមសារ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី បានចុះហត្ថលេខាជាមួយប្រទេសដទៃ។ កំណត់វិស័យអាទិភាព ដែលត្រូវដាក់ចូលទៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី។
- ធ្វើជាសេនាធិការដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមានឡើងនៅក្នុងពេលនៃកិច្ចសហប្រតិបត្តិការ តាមរយៈការចរចា។
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាលតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។
- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល។

**ប្រការ ៥.**_

ក្រុមការងាររួមកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី សម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម វិនិយោគ និងសេដ្ឋកិច្ចកម្ពុជា-សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានក្រុមការងារអវត្តមាន ប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

## ជំពូកទី៤
## ការប្រព្រឹត្តទៅ

**ប្រការ ៦.**

ក្រុមការងាររួមកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី អាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន វិស័យឯកជន អ្នកជំនាញការជាតិ និងអន្តរជាតិ ឬភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមប្រជុំ ឬផ្តល់យោបល់តាមការចាំបាច់។

**ប្រការ ៧.**_

ប្រធានក្រុមការងាររួមកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី មានសិទ្ធិបង្កើតអនុក្រុមការងារតាមការចាំបាច់ ដើម្បីជួយបំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់។

សមាសភាព និងតួនាទីភារកិច្ចរបស់អនុក្រុមការងាររួមកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមការងាររួមកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី។

**ប្រការ ៨.**_

ក្រុមការងាររួមកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី មាននាយកដ្ឋានអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក នៃក្រសួងពាណិជ្ជកម្មជាលេខាធិការដ្ឋាន។

**ប្រការ ៩.**_

ក្រុមការងាររួមកម្ពុជា-គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្មក្នុងការបំពេញការងាររបស់ខ្លួន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- សាមីខ្លួន (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១០ សរ.......

# សារាចរ

## ស្តីពី

## ការថែរក្សា ការពារបង្គោលព្រំដែនចាស់ បោះដោយគណៈកម្មការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងកូសាំងស៊ីន នៅមុន និងក្រោយ ទសវត្សរ៍ឆ្នាំ១៨៧០

ដើម្បីជៀសវាងការបាត់បង់នូវមរតកប្រវត្តិសាស្ត្រ ដែលជាផ្នែកមួយនៃសាវតាជាតិខ្មែរ និងការសឹករេចរឹលដោយធម្មជាតិ និងដើម្បីថែរក្សា ការពារបង្គោលព្រំដែនចាស់ដែលបោះដោយគណៈកម្មការកំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងកូសាំងស៊ីន នៅមុន និងក្រោយទសវត្សឆ្នាំ១៨៧០ ឲ្យបានឋិតថេរគង់វង្ស ទុកឲ្យកូនចៅជំនាន់ក្រោយៗបានឃើញអតីតបង្គោលព្រំដែនទាំងនោះ និងធ្វើការប្រៀបធៀបជាមួយនឹងបង្គោលព្រំដែនបោះនៅជំនាន់ក្រោយនេះ នៅពេលដែលកម្ពុជាមានអធិបតេយ្យភាពពេញលេញក្នុងការធ្វើព្រំដែនជាមួយនឹងប្រទេសជិតខាង ដែលជាមោទនភាពជាតិមួយ ទុកសម្រាប់ខ្មែរជំនាន់ក្រោយជានិរន្តរ៍តទៅ។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការដូចខាងក្រោម៖

១-គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ចាំបាច់ត្រូវរក្សាបង្គោលព្រំដែនចាស់ទាំងឡាយនោះឲ្យបានគង់វង្ស ទោះជាមានសភាពទ្រុឌទ្រោមកំរិតណាក៏ដោយ

២-គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ត្រូវសហការជាមួយនឹងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ រក្សាទុកបង្គោលព្រំដែនចាស់ដែលបាក់ចេញពីគ្រឹះរបស់វា នៅកន្លែងមួយដែលមានសុវត្ថិភាព ដើម្បីទុកឲ្យប្រជាពលរដ្ឋទូទៅបានឃើញ និងស្គាល់

៣-ក្នុងករណីដែលបង្គោលចាស់ទាំងនោះ បាក់ចេញពីគ្រឹះ ដែលពុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្ពុជា គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន មានភារកិច្ចធ្វើការចរចាជាមួយភាគីវៀតណាមស្នើយកបង្គោលព្រំដែនទាំងនោះ មករក្សាទុកនៅកម្ពុជា

៤-គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ រួមនឹងប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយព្រំដែន ត្រូវសហការគ្នា ដើម្បីស្វែងរកបង្គោល ឬគ្រឹះបង្គោលព្រំដែនចាស់

ដែលអាចនៅសេសសល់ ដើម្បីប្រមូល ឬចងក្រងទុកជាឯកសារស្រាវជ្រាវ

៥-អាជ្ញាធរដែនដី ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋ ត្រូវសហការជាមួយនឹងគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន ដើម្បីថែរក្សា និងការពារបង្គោលព្រំដែនដែលប្រទេសទាំងពីរបានឯកភាពគ្នាបោះលើដីជាក់ស្តែងរួចហើយ ឲ្យបានឋិតឋេរគង់វង្សតរៀងទៅ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្ត ក្រុង ឃុំ សង្កាត់ ដែលជាប់ព្រំដែន មន្ទីរ និងអង្គភាពជំនាញជុំវិញខេត្តដែលជាប់ព្រំដែន ត្រូវចាត់ចែងឲ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិកាដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ**សម្តេចតេជោ** នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
-គ្រប់រដ្ឋបាលខេត្តជាប់ព្រំដែន
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...០៥...ស.ណ.ណន

## សារាចរណែនាំ
## ស្តីពី
## វិធានការចាំបាច់នានាក្នុងការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ

រាជរដ្ឋាភិបាលបាន និងកំពុងធ្វើកំណែទម្រង់ស៊ីជម្រៅលើការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសទៅលើវិស័យព្រៃឈើ និងជលផល តាមរយៈការជំរុញឱ្យមានការធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ  ក៏ដូចជាការបែងចែកឡើងវិញនូវសមត្ថកិច្ចឱ្យបានច្បាស់លាស់រវាងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ ព្រមទាំងរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជានានូវការលើកកម្ពស់ប្រសិទ្ធភាព និងនិរន្តរភាពនៃការគ្រប់គ្រងធនធានធម្មជាតិ។

ជាមួយគ្នានេះដែរ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានសម្រេចផ្ទេរ និងប្រគល់សមត្ថកិច្ចគ្រប់គ្រងតំបន់ការពារ និងអភិរក្សព្រៃឈើទាំងអស់ទៅឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និងសមត្ថកិច្ចគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចទាំងអស់  ទៅឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងបានដាក់បញ្ចូលតំបន់ព្រៃឈើមួយចំនួនបន្ថែមទៀតឱ្យក្លាយទៅជាតំបន់ការពារធម្មជាតិ។

ស្របពេលនឹងការផ្ទេរសមត្ថកិច្ចគ្រប់គ្រងតំបន់ទាំងនេះ   និងការជំរុញឱ្យមានការធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា បុគ្គលមួយចំនួនបាន និងកំពុងឆ្លៀតឱកាសប្រព្រឹត្តបទល្មើសធនធានធម្មជាតិដ៏គួរឱ្យព្រួយបារម្ភនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិ។ ដើម្បីធានាបានប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងដំណាក់កាលនេះ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការចាំបាច់នានា ដូចខាងក្រោមៈ

១. អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈគណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវដឹកនាំ សម្របសម្រួលកម្លាំងអធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ អធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលជលផល មន្ទីរបរិស្ថាន និងកងកម្លាំងមានសមត្ថកិច្ចនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យអនុវត្តឱ្យបានត្រឹមត្រូវនូវតួនាទីភារកិច្ចរបស់ខ្លួនសំដៅពង្រឹងសមត្ថកិច្ច និងការទទួលខុសត្រូវរបស់គណៈបញ្ជាការឯកភាពគ្រប់ថ្នាក់ចំពោះរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង  ការថែរក្សា  និងការ

ការពារធនធានធម្មជាតិ ដោយត្រូវចាត់វិធានការឱ្យបានហ្មត់ចត់ក្នុងការទប់ស្កាត់ ការបង្ក្រាប និងការលុបបំបាត់បទល្មើសធនធានធម្មជាតិគ្រប់ប្រភេទ រួមទាំងការរុករានដីនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

២. អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កលទ្ធភាព និងលើកទឹកចិត្តឱ្យសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាចូលរួមទប់ស្កាត់ និងលុបបំបាត់បទល្មើសធនធានធម្មជាតិគ្រប់ប្រភេទនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗត្រូវរៀបចំកិច្ចប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងអង្គការសង្គមស៊ីវិល អង្គការសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានាឱ្យបានយ៉ាងតិចម្តងក្នុងមួយត្រីមាស ឬអាចកោះប្រជុំតាមការចាំបាច់ ដើម្បីពិនិត្យពិភាក្សាអំពីស្ថានភាពនៃការគ្រប់គ្រងធនធានធម្មជាតិ និងដើម្បីចាត់វិធានការដាក់ស្តែងនានាក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

៣. ប្រគល់សមត្ថកិច្ចដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការឱ្យបានម៉ឺងម៉ាត់ និងហ្មត់ចត់ ដូចខាងក្រោម៖

- គ្រប់គ្រងរាល់សិប្បកម្មកែច្នៃ និងអាជីវកម្មធនធានព្រៃឈើ និងផលផលដែលមានច្បាប់អនុញ្ញាត ព្រមទាំងទប់ស្កាត់ និងលុបបំបាត់សិប្បកម្មកែច្នៃ និងអាជីវកម្មធនធានព្រៃឈើ និងផលផលដែលគ្មានច្បាប់អនុញ្ញាត
- ត្រួតពិនិត្យ និងចាត់វិធានការលុបបំបាត់ការដឹកជញ្ជូន និងការស្តុកឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃពីឈើគ្រប់ប្រភេទព្រមទាំងសត្វព្រៃដែលគ្មានការអនុញ្ញាតត្រឹមត្រូវតាមច្បាប់ ទៅក្រៅប្រទេសតាមច្រកព្រំដែន និងតាមច្រករបៀង
- ដឹកនាំ សម្របសម្រួលអធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ អធិការ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលជលផល មន្ទីរបរិស្ថាន និងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធទាំងឡាយ ដើម្បីធានាបាននូវការប្រើប្រាស់កម្លាំងសរុប និងមធ្យោបាយចាំបាច់នានាក្នុងការថែរក្សា និងការពារធនធានធម្មជាតិព្រមទាំងទប់ស្កាត់ និងបង្ក្រាបសកម្មភាពបទល្មើសនៅក្នុងតំបន់ការពារ និងអភិរក្សធម្មជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើរបាយការណ៍បូកសរុបប្រចាំត្រីមាស ឬធ្វើរបាយការណ៍ក្នុងករណីចាំបាច់ អំពីស្ថានភាពនៃការគ្រប់គ្រងតំបន់ការពារ និងអភិរក្សធម្មជាតិនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជូនក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយត្រូវចម្លងជូនក្រសួងមហាផ្ទៃ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស។ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវធ្វើការបូកសរុបរបាយការណ៍ទាំងនេះ ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានរដ្ឋបាលព្រៃឈើជាសេនាធិការត្រូវត្រួតពិនិត្យ និងពង្រឹងការគ្រប់គ្រងឱ្យបានម៉ឺងម៉ាត់នូវការចេញលិខិតអនុញ្ញាតដឹកជញ្ជូនផល និងអនុផលព្រៃឈើគ្រប់ប្រភេទ ដើម្បីទប់ស្កាត់ និងលុបបំបាត់ការដឹកជញ្ជូនផល និងអនុផលព្រៃឈើខុសច្បាប់។

៥. ក្រសួងបរិស្ថាន ដោយមានអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាសេនាធិការត្រូវពង្រឹងយន្តការ និងផ្តល់កម្លាំងគាំទ្រដល់គណៈបញ្ជាឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៦. រាល់អន្តរាគមន៍របស់អង្គភាព ឬបុគ្គលដែលគ្មានសមត្ថកិច្ចលើការដឹកជញ្ជូនផល និងអនុផលព្រៃឈើ ត្រូវបានហាមឃាត់ជាដាច់ខាត ហើយនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

៧. ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់កិច្ចសហការ និងគាំទ្រដល់គណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តវិធានការទាំងនេះ។

៨. ក្នុងករណីចាំបាច់ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត អាចស្នើសុំកម្លាំងអន្តរាគមន៍ជាបន្ទាន់មកមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៩. រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារគ្រប់គ្រងធនធានធម្មជាតិរៀងរាល់ត្រីមាស។

គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តសារាចរណែនាំនេះឱ្យបានម៉ឺងម៉ាត់បំផុត និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *គ្រប់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : ៤៤១.....ឧស.ក.រ.ក/ក.រ.ក.១៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៦

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន សាញនីង ថេកស្ទាយ ឧប ។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន សាញនីង ថេកស្ទាយ ឧប (SHINING TEXTILE CORP.) តំណាងដោយ លោក CHUNG, YANG-YU បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រកាត់ដេរសម្លៀកបំពាក់ សាញនីង ថេកស្កាយ ខប "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤:** ប្រកាសលេខ ៤៦១ ឧរ៉ថ.កឧ.ប្រក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន សាញនីង ថេកស្តាយ ខប ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**ហេង សុខគង់**

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ